ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍
អគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍
នាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ

# គោលការណ៍ណែនាំ
# ស្តីពី
# ការវាយតម្លៃស្តង់ដាសណ្ឋាគារបៃតងកម្ពុជា

ឆ្នាំ ២០២១

រៀបចំដោយៈ នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍
គាំទ្រដោយៈ គម្រោងទេសចរណ៍ GMS TIIG II No. 3701-CAM (COL)

# មាតិកា


១. សូចនាករគោលនៃការផ្សព្វផ្សាយគោលការណ៍លើកកម្ពស់គុណភាពបរិស្ថាន និងអនុវត្តសកម្មភាពជាក់ស្តែងសម្រាប់ប្រតិបត្តិការអាជីវកម្មសណ្ឋាគារ..................... ១

២. សូចនាករគោលនៃការប្រើប្រាស់ផលិតផលបៃតង.............................................................................................................................................. ៣

៣. សូចនាករគោលនៃការចូលរួមការអភិវឌ្ឍសហគមន៍.......................................................................................................................................... ៦

៤. សូចនាករគោលនៃកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស.......................................................................................................................................... ៨

៥. សូចនាករគោលនៃការគ្រប់គ្រងសំណល់រឹង.................................................................................................................................................. ១១

៦. សូចនាករគោលនៃការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព.................................................................................................................. ១៣

៧. សូចនាករគោលនៃប្រសិទ្ធភាពក្នុងការប្រើប្រាស់ទឹក និងគុណភាពទឹក.......................................................................................................... ១៦

៨. សូចនាករគោលនៃការគ្រប់គ្រងគុណភាពខ្យល់................................................................................................................................................ ១៨

៩. សូចនាករគោលនៃការគ្រប់គ្រងការបំពុលបរិស្ថានដោយសម្លេង........................................................................................................................ ២០

១០. សូចនាករគោលនៃការគ្រប់គ្រង និងការធ្វើប្រព្រឹត្តកម្មសំណល់រាវ.................................................................................................................. ២១

១១. សូចនាករគោលនៃការគ្រប់គ្រងផលិតផល និងសំណល់ ដែលមានសារធាតុគីមី និងជាតិពុល........................................................................ ២២

## ១. សូចនាករគោលនៃការផ្សព្វផ្សាយគោលការណ៍លើកកម្ពស់គុណភាពបរិស្ថាន និងអនុវត្តសកម្មភាពជាក់ស្តែងសម្រាប់ប្រតិបត្តិការអាជីវកម្មសណ្ឋាគារ

| **សូចនាករលម្អិត** | **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **សូចនាករវាស់** | **លក្ខខណ្ឌ** |
|---|---|---|---|
| **១-ការផ្សព្វផ្សាយគោលការណ៍លើកកម្ពស់គុណភាពបរិស្ថាន** | វត្តមានឯកសារគោលការណ៍របស់សណ្ឋាគារសម្រាប់ការលើកកម្ពស់គុណភាពបរិស្ថាន | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានមួយ ដែលតម្រូវឱ្យបុគ្គលិកគ្រប់រូប គ្រប់ថ្នាក់អនុវត្តតាម។ ឯកសារនេះ មានបញ្ជាក់ច្បាស់ពីគោលបំណង និងទិសដៅលទ្ធផលជាក់ស្តែងដែលផ្សារភ្ជាប់នឹងមូលហេតុដើម្បីលើកកម្ពស់គុណភាពបរិស្ថាន | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬបានផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន-មិនមាន** (*) | |
| | វត្តមាននៃការផ្សព្វផ្សាយគោលការណ៍របស់សណ្ឋាគារសម្រាប់ការលើកកម្ពស់គុណភាពបរិស្ថានដល់ភ្ញៀវដែលចូលមកស្នាក់នៅក្នុងសណ្ឋាគារ (**ដាក់បញ្ឈរស្លាកសញ្ញានៅកន្លែងទទួលភ្ញៀវ តាមច្រករបៀង អាងហែលទឹក។ល។**) | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានមួយ ដែលតម្រូវឱ្យបុគ្គលិកគ្រប់រូប គ្រប់ថ្នាក់អនុវត្តតាម។<br>ឯកសារនេះ មានបញ្ជាក់ច្បាស់ពីគោលបំណង និងទិសដៅលទ្ធផលជាក់ស្តែងដែលផ្សារភ្ជាប់នឹងមូលហេតុដើម្បីលើកកម្ពស់គុណភាពបរិស្ថាន។ ខ្លឹមសារសកម្មភាពសំខាន់ៗដើម្បីសម្រេចគោលបំណង និងទិសដៅត្រូវបានផ្សព្វផ្សាយឱ្យដល់ភ្ញៀវទាំងអស់ដែលមកស្នាក់នៅក្នុងសណ្ឋាគារ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- មានបិទផ្សាយ ឬបោះផ្សាយខ្លឹមសារដែលភ្ញៀវអាចមើលឃើញ និងយល់បានដោយងាយស្រួល |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |
| | វត្តមាននៃការផ្សព្វផ្សាយគោលការណ៍របស់សណ្ឋាគារសម្រាប់ការលើកកម្ពស់គុណភាពបរិស្ថានដល់អ្នកផ្គត់ផ្គង់តាមរយៈការកំណត់គោលការណ៍ក្នុងការទិញទំនិញពីអ្នកផ្គត់ផ្គង់ (Purchasing Policy) | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានកំណត់លក្ខខណ្ឌផលិតផលដែលត្រូវទិញ ឬលក្ខខណ្ឌដៃគូសហការ ដោយបូកបញ្ចូលការគិតគូរពីបរិស្ថាន (Green Purchasing Policy)។ និងលក្ខខណ្ឌសំខាន់ៗត្រូវបានរំលឹកនៅក្នុងកិច្ចសន្យាទិញលក់ ឬនៅក្នុងការផ្សព្វផ្សាយជ្រើសរើសដៃគូផ្គត់ផ្គង់ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- មានគំរូកិច្ចសន្យា ឬលិខិតប្រកាសផ្សាយពីលក្ខខណ្ឌជ្រើសរើសដៃគូផ្គត់ផ្គង់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

| | | | |
|---|---|---|---|
| **២- ការរៀបចំកម្មវិធី និងផែនការលើកកម្ពស់ការយល់ដឹងរបស់បុគ្គលិកសណ្ឋាគារស្ដីពីបញ្ហាបរិស្ថាន** | វត្តមានកម្មវិធី ផែនការ ឬកម្មវិធីបណ្ដុះបណ្ដាលបុគ្គលិកសណ្ឋាគារស្ដីពីការលើកកម្ពស់បរិស្ថាន | អាជីវកម្មបានរៀបចំរួចរាល់នូវកម្មវិធី ផែនការ ឬកម្មវិធីបណ្ដុះបណ្ដាលបុគ្គលិកអំពីចំណេះដឹងទាក់ទងនឹងបញ្ហាបរិស្ថានដល់បុគ្គលិកសណ្ឋាគារដូចជាបញ្ហាបម្រែបម្រួលអាកាសធាតុ បញ្ហាសំណល់ ឬការកែច្នៃសំណល់ជាដើម | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- បញ្ជីរាយនាមបុគ្គលិកសរុបតាមផ្នែក និងការបញ្ជាក់ជាភាគរយបុគ្គលិកដែលទទួលបានការបណ្ដុះបណ្ដាល |
| | **ការវាយតម្លៃ** | **មាន -មិនមាន**<br>យ៉ាងហោច៥០%នៃបុគ្គលិកប្រតិបត្តិការផ្ទាល់ | |
| | វត្តមានយន្តការជំរុញ និងលើកទឹកចិត្តឱ្យបុគ្គលិកដែលបំរើការក្នុងសណ្ឋាគារចូលរួមគាំទ្រគោលការណ៍ បរិស្ថានរបស់សណ្ឋាគារ | អាជីវកម្មបាននិងកំពុងអនុវត្តយន្តការ ជាមធ្យោបាយផ្សេងៗដើម្បីជំរុញឱ្យបុគ្គលិកចូលរួមគាំទ្រគោលការណ៍គាំពារបរិស្ថានរបស់សណ្ឋាគារដូចជាការផ្ដល់បណ្ណសរសើរ ឬវត្ថុអនុស្សាវរីយ៍ ថវិកា ឬមធ្យោបាយផ្សេងទៀតចំពោះបុគ្គលិក | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- បញ្ជីរាយនាមបុគ្គលិកដែលទទួលបានការលើកទឹកចិត្ត |
| | **ការវាយតម្លៃ** | **មាន -មិនមាន** | |
| **៣- កម្មវិធីតាមដាននិងត្រួតពិនិត្យក្នុងការគ្រប់គ្រងបរិស្ថានសម្រាប់ដំណើរការអាជីវកម្មសណ្ឋាគារ** | វត្តមានយន្តការតាមដាន វាយតម្លៃ និងរបាយការណ៍លទ្ធផលស្ដីពីការអនុវត្តគោលការណ៍របស់សណ្ឋាគារសម្រាប់លើកកម្ពស់គុណភាពបរិស្ថាន | អាជីវកម្មបាននិងកំពុងអនុវត្តយន្តការតាមដាន វាយតម្លៃ លទ្ធផល និងប្រសិទ្ធភាពអនុវត្តនូវរាល់គោលការណ៍មូលដ្ឋានគ្រឹះ ដើម្បីគាំពារបរិស្ថានដែលអាជីវកម្មបានសម្រេចដាក់ចេញកន្លងមក និងត្រូវកំណត់ផងដែរនូវអង្គទទួលខុសត្រូវតាមដានវាយតម្លៃ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- របាយការណ៍វាយតម្លៃលទ្ធផលតាមផ្នែក |
| | **ការវាយតម្លៃ** | **មាន -មិនមាន (*)** | |

## ២. សូចនាករគោលនៃការប្រើប្រាស់ផលិតផលបៃតង

| **សូចនាករលម្អិត** | **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **សូចនាករវាស់** | **លក្ខខណ្ឌ** |
|---|---|---|---|
| **៤-ការជំរុញ និងលើកទឹកចិត្តឱ្យប្រើប្រាស់ផលិតផលក្នុងស្រុកសម្រាប់ប្រតិបត្តិការអាជីវកម្មសណ្ឋាគារ** | វត្ថុមានគោលការណ៍ និងផែនការច្បាស់លាស់ដើម្បីជំរុញ និងលើកទឹកចិត្តក្នុងការប្រើប្រាស់ផលិតផលក្នុងស្រុក | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានមួយដែលគាំទ្រការប្រើប្រាស់ផលិតផលក្នុងស្រុក។ សម្រាប់ប្រតិបត្តិការសណ្ឋាគារ។ ឯកសារនេះ មានបញ្ជាក់ច្បាស់ពីគោលបំណង និងទិសដៅលទ្ធផលជាក់ស្តែង និងជាឯកសារទទួលស្គាល់ដោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់សណ្ឋាគារ។ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន-មិនមាន** (*) | |
| | វត្ថុសិល្បៈ វត្ថុតុបតែង ដែលបំពាក់នៅការិយាល័យជួរមុខជាផលិតផលក្នុងស្រុក | អាជីវកម្មបាននិងកំពុងប្រើប្រាស់ផលិតផលក្នុងស្រុកជាគ្រឿងសម្ភារៈប្រើប្រាស់ ឬសម្រាប់តុបតែងលម្អនៅការិយាល័យជួរមុខ | - មានបញ្ជីឈ្មោះផលិតផលក្នុងស្រុកដែលប្រើប្រាស់នៅការិយាល័យជួរមុខ<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនឹងផលិតផលសរុបដែលកំពុងប្រើប្រាស់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៥0% | |
| | វត្ថុសិល្បៈ វត្ថុតុបតែង ដែលបំពាក់នៅក្នុងបន្ទប់ភ្ញៀវជាផលិតផលក្នុងស្រុក | អាជីវកម្មបាននិងកំពុងប្រើប្រាស់ផលិតផលក្នុងស្រុកជាគ្រឿងសម្ភារៈប្រើប្រាស់ ឬសម្រាប់តុបតែងលម្អនៅក្នុងបន្ទប់ភ្ញៀវ | - មានបញ្ជីឈ្មោះផលិតផលក្នុងស្រុកដែលប្រើប្រាស់នៅក្នុងបន្ទប់ភ្ញៀវ<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនឹងផលិតផលសរុបដែលកំពុងប្រើប្រាស់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៥0% | |

<table>
<tr><td rowspan="2">៤- ការជំរុញ និងលើកទឹកចិត្តឱ្យប្រើប្រាស់ផលិតផលក្នុងស្រុកសម្រាប់ប្រតិបត្តិការអាជីវកម្មសណ្ឋាគារ</td><td>គ្រឿងឧបភោគបរិភោគសម្រាប់ផ្គត់ផ្គង់ជូនភ្ញៀវប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក</td><td>អាជីវកម្មបាននិងកំពុងប្រើប្រាស់ផលិតផលក្នុងស្រុកជាវត្ថុធាតុដើមសម្រាប់រៀបចំជាម្ហូបអាហារជូនភ្ញៀវ</td><td>- មានបញ្ជីឈ្មោះផលិតផលក្នុងស្រុកដែលប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់រៀបចំជាម្ហូបអាហារ<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនិងផលិតផលសរុបដែលកំពុងប្រើប្រាស់</td></tr>
<tr><td>ការវាយតម្លៃ</td><td colspan="2">មាន-មិនមាន<br>យ៉ាងហោច៥០%</td></tr>
<tr><td rowspan="4">៥- ការជំរុញ និងលើកទឹកចិត្តឱ្យប្រើប្រាស់ផលិតផលដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានសម្រាប់ប្រតិបត្តិការអាជីវកម្ម</td><td>វត្តមានគោលការណ៍ និងផែនការច្បាស់លាស់ដើម្បីជំរុញ និងលើកទឹកចិត្តក្នុងការប្រើប្រាស់ផលិតផលដែលមិនប៉ះពាល់ធ្ងន់ធ្ងដល់បរិស្ថានសម្រាប់ប្រតិបត្តិការអាជីវកម្ម</td><td>អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានមួយដែលគាំទ្រការប្រើប្រាស់ផលិតផលដែលមិនប៉ះពាល់ដល់បរិស្ថាន ឬប៉ះពាល់តិចតួចសម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន។ ឯកសារនេះ មានបញ្ជាក់ច្បាស់លាស់ពីគោលបំណង និងទិសដៅលទ្ធផលជាក់ស្តែង និងជាឯកសារទទួលស្គាល់ដោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់សណ្ឋាគារ។</td><td>- មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)</td></tr>
<tr><td>ការវាយតម្លៃ</td><td colspan="2">មាន-មិនមាន (*)</td></tr>
<tr><td>សម្ភារះប្រើប្រាស់សម្រាប់ប្រតិបត្តិការសេវាកម្មការិយាល័យជួរមុខលើកទឹកចិត្តដល់ការប្រើប្រាស់ប្រភេទផលិតផល Eco-friendly Products</td><td>អាជីវកម្មបាននិងកំពុងប្រើប្រាស់ផលិតផលដែលមិនប៉ះពាល់ដល់បរិស្ថាន ឬប៉ះពាល់តិចតួចជាគ្រឿងសម្ភារះប្រើប្រាស់ ឬសម្រាប់តុបតែងលម្អនៅការិយាល័យជួរមុខ</td><td>- មានបញ្ជីឈ្មោះផលិតផលទាំងនោះដែលប្រើប្រាស់នៅការិយាល័យជួរមុខ<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនឹងផលិតផលសរុបដែលកំពុងប្រើប្រាស់</td></tr>
<tr><td>ការវាយតម្លៃ</td><td colspan="2">មាន-មិនមាន<br>យ៉ាងហោច៥០%</td></tr>
</table>

| | | | |
|---|---|---|---|
| **៦- ការជំរុញ និង លើកទឹកចិត្តឱ្យប្រើប្រាស់ផលិតផលដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានសម្រាប់ប្រតិបត្តិអាជីវកម្ម** | ដោយមានឯកសារសំអាង (ឯកសាររបាយការណ៍ ឬជាផែនការនៃការអនុវត្តដែលមានការទទួលស្គាល់ត្រឹមត្រូវ) | ដោយមានឯកសារសំអាង (ឯកសាររបាយការណ៍ ឬជាផែនការនៃការអនុវត្តដែលមានការទទួលស្គាល់ត្រឹមត្រូវ) | - មានបញ្ជីឈ្មោះផលិតផលទាំងនោះដែលប្រើប្រាស់នៅក្នុងបន្ទប់ភ្ញៀវ<br>- មានបញ្ជីឈ្មោះផលិតផលទាំងនោះដែលប្រើប្រាស់សម្រាប់ធ្វើសេវាកម្មសម្អាតបន្ទប់ភ្ញៀវ<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនឹងផលិតផលសរុបដែលកំពុងប្រើប្រាស់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៧០% | |
| | ចូលរួមក្នុងយុទ្ធនាការ **"ទីក្រុងស្អាត ជាទីក្រុងដែលគ្មានសំរាមជាថង់ប្លាស្ទីកហើរតាមខ្យល់"** | អាជីវកម្មបាននិងកំពុងចូលរួមប្រចាំក្នុងយុទ្ធនាការនេះជាមួយអាជ្ញាធរមូលដ្ឋាន ឬរៀបចំដោយអាជីវកម្មផ្ទាល់ ដោយមានជារូបភាពបញ្ជាក់អមជាមួយកាលបរិច្ឆេទចូលរួម ឬមានរៀបចំជាកម្មវិធីកាត់បន្ថយការប្រើប្រាស់ថង់ផ្លាស់ស្ទីក នៅក្នុងការប្រតិបត្តិការអាជីវកម្មសណ្ឋាគារ ដោយមានឯកសារសំអាង (ឯកសាររបាយការណ៍ ឬជាផែនការនៃការអនុវត្តដែលមានការទទួលស្គាល់ត្រឹមត្រូវ) | - មានបញ្ជីឈ្មោះផលិតផលទាំងនោះដែលប្រើប្រាស់នៅការិយាល័យជួរមុខ<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនឹងផលិតផលសរុបដែលកំពុងប្រើប្រាស់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន** (*) | |

## ៣. សូចនាករគោលនៃការចូលរួមការអភិវឌ្ឍសហគមន៍

| សូចនាករលម្អិត | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | សូចនាករទូទៅ | លក្ខខណ្ឌ |
|---|---|---|---|
| ៦- កម្មវិធី និង សកម្មភាពចូលរួម ដល់ការអភិវឌ្ឍ សហគមន៍ | វត្តមានកម្មវិធី និងសកម្មភាព ចូលរួមដល់ការអភិវឌ្ឍសហគមន៍ | អាជីវកម្មបានរៀបចំរួចរាល់នូវកម្មវិធី ផែនការសកម្មភាពជាក់ស្តែង ទាក់ទងនឹងការអភិវឌ្ឍសហគមន៍ ទោះក្នុងរូបភាពណាក៏ដោយ។ កម្មវិធី និងសកម្មភាពទាំងនោះអាចជាការអភិវឌ្ឍរូបវន្ត ឬចំណេះដឹង។ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- បញ្ជីរៀបរាប់សកម្មភាពដែលបានធ្វើ ឬគ្រោងនឹងធ្វើ |
| | ការវាយតម្លៃ | មាន - មិនមាន | |
| | បុគ្គលិកបម្រើការក្នុងផ្នែកប្រតិបត្តិការផ្ទាល់ជាប្រជាសហគមន៍ | អាជីវកម្មបាននិងកំពុងផ្តល់ឱកាសការងារដល់ប្រជាសហគមន៍ផ្ទាល់ឱ្យបម្រើការនៅក្នុងអាជីវកម្មរបស់ខ្លួន | - មានបញ្ជីឈ្មោះបុគ្គលិកទាំងអស់<br>- មានបញ្ជាក់បរិមាណជាភាគរយនូវបុគ្គលិកជាប្រជាសហគមន៍ធៀបនឹងចំនួនបុគ្គលិកសរុប |
| | ការវាយតម្លៃ | មាន - មិនមាន<br>យ៉ាងហោច២០% | |
| | ចូលរួមក្នុងគំរោងអភិវឌ្ឍហេដ្ឋា-រចនាសម្ព័ន្ធសហគមន៍ | អាជីវកម្មបានចូលរួមជាក់ស្តែងជាមួយគំរោងអភិឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍ក្នុងរយៈពេល ៦ខែចុងក្រោយ។ | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់និងបច្ចុប្បន្នភាព ឬមានរូបភាពបញ្ជាក់ |
| | ការវាយតម្លៃ | មាន - មិនមាន | |

| | | | |
|---|---|---|---|
| **៧- កម្មវិធីលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់ប្រជាពលរដ្ឋក្នុងសហគមន៍** | វត្តមានកម្មវិធី ផែនការ ឬកម្មវិធីបណ្តុះបណ្តាលបុគ្គលិកសណ្ឋាគារស្តីពីការលើកកម្ពស់បរិស្ថាន | អាជីវកម្មបានរៀបចំជាកម្មវិធី សកម្មភាពការងារ និងឯកសារសម្រាប់បញ្ជ្រាបការយល់ដឹងអំពីការលើកកម្ពស់គុណភាពបរិស្ថានដល់ប្រជាពលរដ្ឋក្នុងសហគមន៍(ឧ. បញ្ជ្រាបការយល់ដឹងអំពីការកាត់បន្ថយការប្រើប្រាស់ថង់ផ្លាស្ទិក ការកែច្នៃសំណល់ ឬវិធីសាស្ត្រកាត់បន្ថយសំណល់ជាដើម)។ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន -មិនមាន (*)** | |
| | ការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថានដល់ប្រជាសហគមន៍ដោយផ្ទាល់ | អាជីវកម្មបានចូលរួមជាក់ស្តែងនិងដោយផ្ទាល់ ក្នុងសកម្មភាពបណ្តុះបណ្តាលនិងបញ្ជ្រាបការយល់ដឹងអំពីបរិស្ថានដល់ប្រជាសហគមន៍ក្នុងរយៈពេល១ឆ្នាំចុងក្រោយ។ | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់និងបច្ចុប្បន្នភាព ឬមានរូបភាពបញ្ជាក់ |
| | **ការវាយតម្លៃ** | **មាន -មិនមាន**<br>**យ៉ាងហោច១ដងក្នុង១ឆ្នាំ** | |
| | ការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថានដល់ប្រជាសហគមន៍ដោយប្រយោល | អាជីវកម្មបានចូលរួមដោយប្រយោល ក្នុងសកម្មភាពបណ្តុះបណ្តាលនិងបញ្ជ្រាបការយល់ដឹងអំពីបរិស្ថានដល់ប្រជាសហគមន៍ក្នុងរយៈពេល៦ខែចុងក្រោយ។ | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់និងបច្ចុប្បន្នភាព ឬមានរូបភាពបញ្ជាក់ |
| | **ការវាយតម្លៃ** | **មាន -មិនមាន** | |
| **៨- ការចូលរួមលើកកម្ពស់វប្បធម៌ ប្រពៃណី ទំនៀមទំលាប់របស់ប្រជាពលរដ្ឋក្នុងសហគមន៍** | វត្តមានយន្តការ ផែនការថែរក្សាលើកកម្ពស់វប្បធម៌ប្រពៃណី ទំនៀមទំលាប់ និងលក្ខណៈពិសេសសម្រាប់សហគមន៍ | អាជីវកម្មបានរៀបចំជាយន្តការ ផែនការថែរក្សាលើកកម្ពស់វប្បធម៌ប្រពៃណី ទំនៀមទំលាប់ និងលក្ខណៈពិសេសសម្រាប់សហគមន៍។ យន្តការ ឬផែនការនោះត្រូវកំណត់ទិសដៅលទ្ធផលច្បាស់លាស់។ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន -មិនមាន** | |

| | | | |
|---|---|---|---|
| **៨-ការចូលរួមលើកកម្ពស់វប្បធម៌ ប្រពៃណី ទំនៀមទំលាប់របស់ប្រជាពលរដ្ឋក្នុងសហគមន៍** | ការបង្ហាញសិល្បៈ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដល់ភ្ញៀវទេសចរ | អាជីវកម្មបានរៀបចំកាលវិភាគច្បាស់លាស់(យ៉ាងហោច ២ដង/សប្តាហ៍) អំពីកម្មវិធីបង្ហាញ (នៅនឹងកន្លែងឬនាំទៅទស្សនា) សិល្បៈ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដល់ភ្ញៀវទេសចរ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច២ដង/សប្តាហ៍ | |
| | ការផ្សព្វផ្សាយអំពីសិល្បៈ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ដល់ភ្ញៀវទេសចរ | អាជីវកម្មបានប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីផ្សព្វផ្សាយ វប្បធម៌ ប្រព្រៃណី ទំនៀមទម្លាប់ដល់ភ្ញៀវដែលមកស្នាក់នៅក្នុងសណ្ឋាគារ តាមរយៈការដាក់តាំងវត្ថុសិល្បៈ ការស្លៀកសម្លៀកបំពាក់ប្រពៃណីសម្រាប់បុគ្គលិកជួរមុខ ឬមានមធ្យោបាយនៃការផ្សព្វផ្សាយផ្សេងទៀត | - មានរូបភាពបញ្ជាក់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

## ៤. សូចនាករគោលនៃកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស

| សូចនាករលម្អិត | លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ | សូចនាកររង្វាស់ | លក្ខខណ្ឌ |
|---|---|---|---|
| ៩- ការរៀបចំកម្មវិធីបណ្តុះបណ្តាលបុគ្គលិក | វត្តមានឯកសារបណ្តុះបណ្តាលសម្រាប់បុគ្គលិក | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារសម្រាប់បណ្តុះបណ្តាលបុគ្គលិកទៅតាមមុខជំនាញ និងការយល់ដឹងជាសាធារណៈដែលចាំបាច់ និងតម្រូវ។ ឯកសារបណ្តុះបណ្តាលអាចជា ឯកសារសម្រាប់បណ្តុះបណ្តាលនៅមុនពេលចាប់ផ្តើមការងារ (Orientation course) ឬកំឡុងពេលប្រតិបត្តិការងារ (Refreshment course) | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | ការវាយតម្លៃ | មាន-មិនមាន (*) | |

| | | | |
|---|---|---|---|
| **៩-ការរៀបចំកម្មវិធីបណ្តុះបណ្តាលបុគ្គលិក** | ការបណ្តុះបណ្តាលវគ្គវិក្រឹត្យការជំនាញ ដល់បុគ្គលិកប្រតិបត្តិការផ្ទាល់ | អាជីវកម្មបានរៀបចំរួចរាល់នូវកម្មវិធី ឬបានបញ្ជូនបុគ្គលិកចូលរួមវគ្គវិក្រឹត្យការលើជំនាញដែលត្រូវអនុវត្ត | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់និងបច្ចុប្បន្នភាព<br>- មានបញ្ជីរាយនាមបុគ្គលិកដែលបានចូលរួមវគ្គវិក្រឹត្យការ និងមានបញ្ជាក់ចំនួនជាភាគរយ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៥០% | |
| | ការបណ្តុះបណ្តាលវគ្គខ្លីពាក់ព័ន្ធនឹងជំនាញ ដល់បុគ្គលិកប្រតិបត្តិការផ្ទាល់ | អាជីវកម្មបានរៀបចំរួចរាល់នូវកម្មវិធី ឬបានបញ្ជូនបុគ្គលិកចូលរួមវគ្គខ្លីលើជំនាញដែលត្រូវអនុវត្ត | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់ លាស់ និងបច្ចុប្បន្នភាព<br>- មានបញ្ជីរាយនាមបុគ្គលិកដែលបានចូលរួមវគ្គខ្លី និងមានបញ្ជាក់ចំនួនជាភាគរយ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៣០% | |
| | ការបណ្តុះបណ្តាលអំពីចំណេះដឹងទូទៅ ដល់បុគ្គលិកប្រតិបត្តិការផ្ទាល់ | អាជីវកម្មបានរៀបចំរួចរាល់នូវកម្មវិធីបណ្តុះបណ្តាល ឬបានបញ្ជូនបុគ្គលិលកចូលរួមការបណ្តុះបណ្តាលអំពីចំណេះដឹងទូទៅ (General knowledge) ដូចជាការស្រាវជ្រាវថ្មីៗ ការធ្វើអនាម័យ ខ្លួនប្រាណ ការស្លៀកពាក់ ការប្រាស្រ័យទាក់ទងជាដើម  និងឯកសារបណ្តុះបណ្តាលវគ្គខ្លីដោយមានភ្ជាប់កាលវិភាគសិក្សា។ | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់និងបច្ចុប្បន្នភាព<br>- មានបញ្ជីរាយនាមបុគ្គលិកដែលបានចូលរួមវគ្គ និងមានបញ្ជាក់ចំនួនជាភាគរយ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៣០% | |

| | | | |
|---|---|---|---|
| **១០- ការរៀបចំកម្មវិធីផ្សព្វផ្សាយបណ្ដុះបណ្ដាលបន្តអំពីសង្គម** | វត្តមានឯកសារផ្សព្វផ្សាយបណ្ដុះបណ្ដាលបន្តអំពីសង្គម | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារសម្រាប់ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលអំពីសង្គមសម្រាប់បុគ្គលិករបស់ខ្លួន។ ឧទាហរណ៍៖ បញ្ហាគ្រឿងញៀន ការបញ្ចៀបយែនឌ័រ ការជួញដូរស្ត្រី និងកុមារ ជាដើម។ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន-មិនមាន (*)** | |
| | ការបណ្ដុះបណ្ដាលបុគ្គលិកជាជនបង្គោល ផ្សព្វផ្សាយបន្តចំណេះដឹងពាក់ព័ន្ធនឹងសង្គម | អាជីវកម្មបានចាត់តាំងនិងបណ្ដុះបណ្ដាលបុគ្គលិកបង្គោលសម្រាប់ការផ្សព្វផ្សាយបន្តចំណេះដឹងពាក់ព័ន្ធនឹងសង្គម។ | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់និងបច្ចុប្បន្នភាព ឬរូបភាព<br>- មានបញ្ជីរាយនាមបុគ្គលិកដែលបានចូលរួមវគ្គ |
| | **ការវាយតម្លៃ** | **មាន-មិនមាន<br>យ៉ាងហោច៥នាក់** | |
| | វត្តមានកម្មវិធីផ្សព្វផ្សាយបណ្ដុះបណ្ដាលបន្តអំពីសង្គម | អាជីវកម្មបានរៀបចំរួចរាល់នូវកម្មវិធីផ្សព្វផ្សាយបណ្ដុះបណ្ដាលបន្ត ឬបានបញ្ជូនបុគ្គលិកចូលរួមការបណ្ដុះបណ្ដាលអំពីសង្គម | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់ និងបច្ចុប្បន្នភាព ឬមានរូបភាពបញ្ជាក់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

## ៥. សូចនាករគោលនៃការគ្រប់គ្រងសំណល់រឹង

| សូចនាករលម្អិត | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | សូចនាករវាស់ | លក្ខខណ្ឌ |
|---|---|---|---|
| ១១- ការណែនាំពន្យល់បង្ហាញអំពីបច្ចេកទេសក្នុងការគ្រប់គ្រងកាកសំណល់ឱ្យមានប្រសិទ្ធភាព | វត្តមានគោលការណ៍អំពីបច្ចេកទេសរបៀប និងវិធីសាស្ត្រងាយៗសម្រាប់ការគ្រប់គ្រងកាកសំណល់រឹង | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារបច្ចេកទេសអំពីរបៀប និងវិធីសាស្ត្រងាយៗរបស់សណ្ឋាគារសម្រាប់ការគ្រប់គ្រងកាកសំណល់រឹង ដូចជាការកាត់បន្ថយកាកសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃកាកសំណល់ ការបែងចែកកាកសំណល់ និងការធ្វើកំប៉ុសសកម្ម ជាដើម | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | ការវាយតម្លៃ | មាន -មិនមាន (*) | |
| | ការកាត់បន្ថយកាកសំណល់ផ្ទះបាយតាមរយៈការកែច្នៃកាកសំណល់ (កំប៉ុស្តកម្ម) | អាជីវកម្មបានអនុវត្តការកែច្នៃសំណល់ផ្ទះបាយ ដូចជាម្ហូបអាហារ ផ្លែឈើ ត្រី សាច់នៅសល់ ឬខូចគុណភាពសម្រាប់ធ្វើកំប៉ុស្តកម្ម | - ទីតាំងធ្វើកំប៉ុស្ត<br>- ការបង្ហាញពីវិធីសាស្ត្រ និងលទ្ធផលសម្រេចបានគិតជាមធ្យម |
| | ការវាយតម្លៃ | មាន -មិនមាន<br>យ៉ាងហោច៥0% | |
| | ការកាត់បន្ថយកាកសំណល់តាមរយៈការកែច្នៃកាកសំណល់ដើម្បីប្រើប្រាស់ឡើងវិញ (Recycle) | អាជីវកម្មបានអនុវត្តការកែច្នៃសំណល់ដោយយកកាកសំណល់មកកែច្នៃដើម្បីប្រើប្រាស់ឡើងវិញដូចជា ការកែច្នៃសំបកដបជ័រ ក្រដាស ដែក កំប៉ុង ទៅជាផលិតផលថ្មីមួយ ដើម្បីប្រើប្រាស់ | - ទីតាំងកែច្នៃ ឬវត្ថុកែច្នៃរួច<br>- ការបង្ហាញពីវិធីសាស្ត្រ និងលទ្ធផលសម្រេចបានគិតជាមធ្យម |
| | ការវាយតម្លៃ | មាន -មិនមាន<br>យ៉ាងហោច៥0% | |

| | | | |
|---|---|---|---|
| **១១-ការណែនាំពន្យល់បង្ហាញអំពីបច្ចេកទេសក្នុងការគ្រប់គ្រងកាកសំណល់ឱ្យមានប្រសិទ្ធភាព** | ការបែងចែក និងទុកដាក់សំណល់រឹងទៅតាមប្រភេទនីមួយៗ | អាជីវកម្មបានអនុវត្តការបែងចែក និងទុកដាក់សំណល់រឹងទៅតាមប្រភេទ ដូចជាៈ ប្រភេទសំណល់សើម (សំណល់ម្ហូបអាហារ ផ្លែឈើ ស្លឹកឈើ។ល។) ប្រភេទសំណល់ស្ងួត (ក្រណាត់ ក្រដាស ប្លាស់ស្ទិក កំប៉ុង ឬកែវ។ល។) និងប្រភេទសំណល់គីមី ឬសំណល់គ្រោះថ្នាក់ (ថ្មពិល គ្រឿងអគ្គីសនី។ល។) ឬប្រភេទផ្សេងទៀត ដែលស្របទៅតាមវិធីសាស្ត្រគ្រប់គ្រងសំណល់រឹងដែលតម្រូវ និងមានរៀបចំជាស្លាកសញ្ញាបិទនៅលើធុងសំរាមដែលមានព័ត៌ខុសៗគ្នានៅតាមទីកន្លែងសាធារណៈ ក្នុងអាជីវកម្ម | - ទីតាំងបែងចែកសំណល់រឹង<br>- ការបង្ហាញពីវិធីសាស្ត្រ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោចមានការបែងចែកជា ០៣ប្រភេទ | |
| | ការប្រើប្រាស់វត្ថុជំនួសដែលប្រើប្រាស់បានច្រើនដងជាង | អាជីវកម្មបាននិងកំពុងប្រើប្រាស់ផលិតផលជំនួស ដែលប្រើប្រាស់បានច្រើនដង ដើម្បីកាត់បន្ថយការប្រើប្រាស់វត្ថុ ឬសម្ភារៈដែលអាចប្រើប្រាស់បានតិចដង (១ ឬ២ដង)។ ដូចជា ដបថ្ម កែវថ្ម ថង់បរិស្ថាន ឬវត្ថុផ្សេងទៀត | - បញ្ជីរាយនាមផលិតផលជំនួសដែលប្រើប្រាស់បានច្រើនដង ដែលបាននិងកំពុងប្រើប្រាស់ ដោយមានបញ្ជាក់ចំនួនច្បាស់លាស់<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |
| | សកម្មភាពចូលរួមដល់ការកាត់បន្ថយកាកសំណល់ | អាជីវម្មបាននិងកំពុងធ្វើសកម្មភាពចូលរួមការកាត់បន្ថយកាកសំណល់ តាមរយៈការប្រើប្រាស់វត្ថុកែច្នៃពីកាកសំណល់ (Recycling) ការប្រើប្រាស់វត្ថុ ឬសម្ភារៈដែលមានគុណភាពខ្ពស់មិនងាយបែកបាក់ ឬខូច ការបរិច្ចាកសម្ភារៈចាស់ៗដល់ជនដទៃ ឬសកម្មភាពផ្សេងទៀតដែលចូលរួមការកាត់បន្ថយកាកសំណល់ | - បញ្ជីរៀបរាប់សកម្មភាពចូលរួមរាយនាមផលិតផលជំនួសដែលប្រើប្រាស់បានច្រើនដង ដែលបាននិងកំពុងប្រើប្រាស់ ដោយមានបញ្ជាក់ចំនួនច្បាស់លាស់<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

| | | | |
|---|---|---|---|
| **១២-ការជម្រុញនិងលើកទឹកចិត្តឱ្យបុគ្គលិកសណ្ឋាគារចូលរួមគាំទ្រយុទ្ធសាស្ត្រគ្រប់គ្រងកាកសំណល់ឱ្យមានប្រសិទ្ធភាព** | វត្តមាននៃការជម្រុញ និងលើកទឹកចិត្តឱ្យបុគ្គលិកសណ្ឋាគារចូលរួម និងគាំទ្រកម្មវិធីកាត់បន្ថយកាកសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃកាកសំណល់ ការបែងចែកកាកសំណល់ និងការធ្វើកំប៉ុសសកម្ម | អាជីវកម្មបាននិងកំពុងអនុវត្តយន្តការ ជាមធ្យោបាយផ្សេងៗដើម្បីជំរុញឱ្យបុគ្គលិកចូលរួមគាំទ្រកម្មវិធីកាត់បន្ថយកាកសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃកាកសំណល់ ការបែងចែកកាកសំណល់ និងការធ្វើកំប៉ុសសកម្ម | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- បញ្ជីរាយនាមបុគ្គលិកដែលធ្លាប់ទទួលបានការលើកទឹកចិត្ត |
| | **ការវាយតម្លៃ** | **មាន-មិនមាន** (*) | |
| **១៣-ការជម្រុញនិងលើកទឹកចិត្តឱ្យភ្ញៀវចូលរួមគាំទ្រយុទ្ធសាស្ត្រគ្រប់គ្រងកាកសំណល់ឱ្យមានប្រសិទ្ធភាព** | វត្តមាននៃការជម្រុញ និងលើកទឹកចិត្តឱ្យភ្ញៀវទេសចរចូលរួម និងគាំទ្រកម្មវិធីកាត់បន្ថយកាកសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃកាកសំណល់ ការបែងចែកកាកសំណល់ និងការធ្វើកំប៉ុសសកម្ម | អាជីវកម្មបាននិងកំពុងអនុវត្តយន្តការ ជាមធ្យោបាយផ្សេងៗដើម្បីជំរុញឱ្យភ្ញៀវចូលរួមគាំទ្រកម្មវិធីកាត់បន្ថយកាកសំណល់ ការប្រើប្រាស់ឡើងវិញ ការកែច្នៃកាកសំណល់ ការបែងចែកកាកសំណល់ និងការធ្វើកំប៉ុសសកម្ម | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- បញ្ជីរៀបរាប់ប្រភេទនៃការលើកទឹកចិត្តដល់ភ្ញៀវ |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

## ៦.    សូចនាករគោលនៃការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព

| សូចនាករលម្អិត | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | សេចក្ដីពន្យល់ | ការវាយតម្លៃ |
|---|---|---|---|
| **១៤-ការណែនាំបុគ្គលិកអំពីបច្ចេកទេស និងការប្រើប្រាស់ឧបករណ៍ដែលជួយសន្សំសំចៃថាមពល** | វត្តមានគោលការណ៍កំណត់បច្ចេកទេស និងការប្រើប្រាស់ឧបករណ៍ដែលជួយសន្សំសំចៃថាមពល | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានមួយ ដែលតម្រូវឱ្យបុគ្គលិកគ្រប់រូប គ្រប់ថ្នាក់អនុវត្តតាម។ ឯកសារនេះ មានបញ្ជាក់ច្បាស់ពីគោលបំណង និងទិសដៅលទ្ធផលជាក់ស្ដែងដែលផ្សារភ្ជាប់នឹងមូលហេតុដើម្បីសន្សំសំចៃថាមពល ឬប្រើប្រាស់ដោយការទទួលខុសត្រូវតាមរយៈការជ្រើសរើសឧបករណ៍អេឡិចត្រូនិចដែលត្រឹមត្រូវ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន-មិនមាន** (*) | |

| | | | |
|---|---|---|---|
| **១៤- ការណែនាំបុគ្គលិកអំពីបច្ចេកទេស និងការប្រើប្រាស់ឧបករណ៍ដែលជួយសន្សំសំចៃថាមពល** | ការប្រើប្រាស់បច្ចេកទេស ឬឧបករណ៍ដែលជួយសន្សំសំចៃថាមពលនៅក្នុងបរិវេណការិយាល័យខាងមុខ | អាជីវកម្មបាននិងកំពុងប្រើប្រាស់បច្ចេកទេស ឬឧបករណ៍អេឡិចត្រូនិចដែលជួយសន្សំសំចៃថាមពលសម្រាប់បំពាក់នៅការិយាល័យជួរមុខ | - មានបញ្ជីឈ្មោះបច្ចេកទេស ឬឧបករណ៍អេឡិចត្រូនិចដែលប្រើប្រាស់នៅការិយាល័យជួរមុខ<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនឹងសម្ភារៈសរុបដែលកំពុងប្រើប្រាស់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៥០% | |
| | ការប្រើប្រាស់បច្ចេកទេស ឬឧបករណ៍ដែលជួយសន្សំសំចៃថាមពលនៅក្នុងបន្ទប់ស្នាក់ | អាជីវកម្មបាននិងកំពុងប្រើប្រាស់បច្ចេកទេស ឬឧបករណ៍អេឡិចត្រូនិចដែលជួយសន្សំសំចៃថាមពលសម្រាប់បំពាក់នៅក្នុងបន្ទប់ស្នាក់ | - មានបញ្ជីឈ្មោះបច្ចេកទេស ឬឧបករណ៍អេឡិចត្រូនិចដែលប្រើប្រាស់នៅការិយាល័យជួរមុខ<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនឹងសម្ភារៈសរុបដែលកំពុងប្រើប្រាស់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៥០% | |
| **១៥- របាយការណ៍វឌ្ឍនាភាពការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព** | វត្តមានរបាយការណ៍វឌ្ឍនភាព (លទ្ធផលប្រចាំឆ្នាំ) នៃការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធិភាព | អាជីវកម្មបានរៀបចំជារបាយការណ៍វឌ្ឍនភាព ឬការវិភាគប្រៀបធៀបដែលបញ្ជាក់អំពីភាពខុសគ្នានៃបរិមាណការប្រើប្រាស់ថាមពលប្រចាំឆ្នាំមុននិងក្រោយប្រើប្រាស់បច្ចេកទេស ឬឧបករណ៍ជួយសន្សំសំចៃថាមពល | - មានរបាយការណ៍ ឬការវិភាគប្រៀបធៀបប្រចាំឆ្នាំ<br>- បានបញ្ជាក់ថា មានកាសន្សំសំចៃជាងមុន (មិនមែនមានន័យថា ត្រូវតែប្រើប្រាស់តិចជាងមុននោះទេ) |
| | **ការវាយតម្លៃ** | **មាន-មិនមាន** (*) | |

| | | | |
|---|---|---|---|
| ១៦- ការជម្រុញ និងលើកទឹកចិត្តភ្ញៀវឱ្យចូលរួមប្រើប្រាស់ថាមពលដោយសន្សំសំចៃ | វត្តមានយន្តការលើកទឹកចិត្តភ្ញៀវទេសចរឱ្យប្រើប្រាស់ថាមពលដោយសន្សំសំចៃ | អាជីវកម្មបាននិងកំពុងអនុវត្តយន្តការ ជាមធ្យោបាយផ្សេងៗដើម្បីជំរុញឱ្យភ្ញៀវចូលរួមគាំទ្រនូវរាល់សកម្មភាពដែលចូលរួមដល់ការប្រើប្រាស់ថាមពលដោយសន្សំសំចៃ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- បញ្ជីរៀបរាប់ប្រភេទនៃការលើកទឹកចិត្តដល់ភ្ញៀវ |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |
| | យន្តការត្រូវបានផ្សព្វផ្សាយនៅក្នុងបរិវេណការិយាល័យខាងមុខ | អាជីវកម្មបាននិងកំពុងផ្សព្វផ្សាយយន្តការ ជាមធ្យោបាយផ្សេងៗដើម្បីជំរុញឱ្យភ្ញៀវចូលរួមគាំទ្រនូវរាល់សកម្មភាពដែលចូលរួមដល់ការប្រើប្រាស់ថាមពលដោយសន្សំសំចៃ នៅបរិវេណការិយាល័យខាងមុខ (កន្លែងទទួលភ្ញៀវ) | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់និងបច្ចុប្បន្នភាព ឬរូបភាព<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |
| | យន្តការត្រូវបានផ្សព្វផ្សាយនៅក្នុងបរិវេណបន្ទប់ស្នាក់ | អាជីវកម្មបាននិងកំពុងផ្សព្វផ្សាយយន្តការ ជាមធ្យោបាយផ្សេងៗដើម្បីជំរុញឱ្យភ្ញៀវចូលរួមគាំទ្រនូវរាល់សកម្មភាពដែលចូលរួមដល់ការប្រើប្រាស់ថាមពលដោយសន្សំសំចៃ នៅបរិវេណបន្ទប់ស្នាក់ | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់និងបច្ចុប្បន្នភាព ឬរូបភាព<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

## ៧. សូចនាករគោលនៃប្រសិទ្ធភាពក្នុងការប្រើប្រាស់ទឹក និងគុណភាពទឹក

| សូចនាករលម្អិត | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | សូចនាករវាស់ | លក្ខខណ្ឌ |
|---|---|---|---|
| ១៧- ការណែនាំបុគ្គលិកអំពីបច្ចេកទេស និងការប្រើប្រាស់ឧបករណ៍ដែលជួយសន្សំសំចៃទឹក | វត្តមានគោលការណ៍កំណត់បច្ចេកទេស និងការប្រើប្រាស់ឧបករណ៍ដែលជួយសន្សំសំចៃទឹក | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានមួយ ដែលតម្រូវឱ្យបុគ្គលិកគ្រប់រូប គ្រប់ថ្នាក់អនុវត្តតាម។ ឯកសារនេះមានបញ្ជាក់ច្បាស់ពីគោលបំណង និងទិសដៅលទ្ធផលជាក់ស្តែងដែលផ្សារភ្ជាប់នឹងមូលហេតុដើម្បីសន្សំសំចៃទឹក ឬប្រើប្រាស់ដោយការទទួលខុសត្រូវតាមរយៈការជ្រើសរើសឧបករណ៍ដែលត្រឹមត្រូវ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន - មិនមាន** | |
| | ការប្រើប្រាស់បច្ចេកទេស ឬឧបករណ៍ដែលជួយសន្សំសំចៃទឹកនៅក្នុងបន្ទប់ស្នាក់ | អាជីវកម្មបាននិងកំពុងប្រើប្រាស់បច្ចេកទេស ឬឧបករណ៍ដែលជួយសន្សំសំចៃទឹកសម្រាប់បំពាក់នៅក្នុងបន្ទប់ស្នាក់ | - មានបញ្ជីឈ្មោះបច្ចេកទេស ឬឧបករណ៍ដែលប្រើប្រាស់ក្នុងបន្ទប់ស្នាក់<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនឹងសម្ភារៈសរុបដែលកំពុងប្រើប្រាស់ |
| | **ការវាយតម្លៃ** | **មាន - មិនមាន**<br>យ៉ាងហោច២០% | |
| | វត្តមានរបាយការណ៍វឌ្ឍនភាព (លទ្ធផលប្រចាំឆ្នាំ) ការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធិភាព | អាជីវកម្មបានរៀបចំជារបាយការណ៍វឌ្ឍនភាព ឬការវិភាគប្រៀបធៀបដែលបញ្ជាក់អំពីភាពខុសគ្នានៃបរិមាណការប្រើប្រាស់ទឹកប្រចាំឆ្នាំមុននិងក្រោយប្រើប្រាស់បច្ចេកទេស ឬឧបករណ៍ដែលជួយសន្សំសំចៃទឹក | - មានរបាយការណ៍ ឬការវិភាគប្រៀបធៀបប្រចាំឆ្នាំ<br>- បានបញ្ជាក់ថា មានការសន្សំសំចៃជាងមុន (មិនមែនមានន័យថា ត្រូវតែប្រើប្រាស់តិចជាងមុននោះទេ) |
| | **ការវាយតម្លៃ** | **មាន - មិនមាន** (*) | |

| | | | |
|---|---|---|---|
| **១៩- ការជម្រុញនិងលើកទឹកចិត្តភ្ញៀវឱ្យចូលរួមប្រើប្រាស់ទឹកដោយសន្សំសំចៃ** | វត្តមានយន្តការលើកទឹកចិត្តភ្ញៀវទេសចរឱ្យប្រើប្រាស់ទឹកដោយសន្សំសំចៃ | អាជីវកម្មបាននិងកំពុងអនុវត្តយន្តការ ជាមធ្យោបាយផ្សេងៗដើម្បីជំរុញឱ្យភ្ញៀវចូលរួមគាំទ្រនូវរាល់សកម្មភាពដែលចូលរួមដល់ការប្រើប្រាស់ទឹកដោយសន្សំសំចៃ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- បញ្ជីរៀបរាប់ប្រភេទនៃការលើកទឹកចិត្តដល់ភ្ញៀវ |
| | **ការវាយតម្លៃ** | **មាន -មិនមាន (*)** | |
| | យន្តការត្រូវបានផ្សព្វផ្សាយនៅក្នុងបរិវេណការិយាល័យខាងមុខ | អាជីវកម្មបាននិងកំពុងផ្សព្វផ្សាយយន្តការជាមធ្យោបាយផ្សេងៗដើម្បីជំរុញឱ្យភ្ញៀវចូលរួមគាំទ្រនូវរាល់សកម្មភាពដែលចូលរួមដល់ការប្រើប្រាស់ទឹកដោយសន្សំសំចៃ នៅបរិវេណការិយាល័យខាងមុខ (កន្លែងទទួលភ្ញៀវ) | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន -មិនមាន**<br>**យ៉ាងហោច១ដងក្នុង១ឆ្នាំ** | |
| | យន្តការត្រូវបានផ្សព្វផ្សាយនៅក្នុងបរិវេណបន្ទប់ស្នាក់ | អាជីវកម្មបាននិងកំពុងផ្សព្វផ្សាយយន្តការផ្សេងៗដើម្បីជំរុញឱ្យភ្ញៀវចូលរួមគាំទ្រនូវរាល់សកម្មភាពដែលចូលរួមដល់ការប្រើប្រាស់ទឹកដោយសន្សំសំចៃ នៅក្នុងបរិវេណបន្ទប់ស្នាក់ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន -មិនមាន** | |

## ៨. សូចនាករគោលនៃការគ្រប់គ្រងគុណភាពខ្យល់

| សូចនាករលម្អិត | លក្ខណៈវិនិច្ឆ័យ | សូចនាករខ្វាស់ | លក្ខខណ្ឌ |
|---|---|---|---|
| ២០- ការបែងចែកកន្លែងដែលភ្ញៀវអាចពិសាបារីបាន និងកន្លែងដែលមិនអនុញ្ញាតឱ្យភ្ញៀវពិសារបារី | ការកំណត់កន្លែងដែលអាចពិសាបារីបាន (Smoking area) និងកន្លែងដែលមិនអាចពិសារបារីបាន (Non-smoking area) នៅក្នុងបរិវេណសណ្ឋាគារដោយមានដាក់ស្លាកសញ្ញា | អាជីវកម្មបានកំណត់ទីតាំងជាក់លាក់ ដោយមានស្លាកសញ្ញាបង្ហាញអំពីទីតាំងអាចពិសាបារី និងកន្លែងដែលមិនអាចពិសាបារី | - មានឯកសារបង្ហាញអំពីទីតាំង ឬស្លាកសញ្ញាបញ្ជាក់<br>- រូបភាព |
| | ការវាយតម្លៃ | មាន - មិនមាន | |
| | ការកំណត់ប្រភេទបន្ទប់ស្នាក់ដែលអាចពិសាបារីបាន (Smoking area) និងបន្ទប់ស្នាក់ដែលមិនអាចពិសាបារី (Non-smoking area) | អាជីវកម្មបានកំណត់ប្រភេទបន្ទប់ស្នាក់ដែលអាចពិសាបារីបាន និងបន្ទប់ស្នាក់ដែលមិនអាចពិសាបារី | - មានបញ្ជីឈ្មោះបន្ទប់ស្នាក់ |
| | ការវាយតម្លៃ | មាន - មិនមាន | |
| ២១- ផែនការត្រួតពិនិត្យ និងតាមដានការបំពុលបរិយាកាសក្នុងដំណើរការអាជីវកម្ម | វត្តមានគោលការណ៍អំពីការថែរក្សា និងទប់ស្កាត់ការបំពុលខ្យល់ | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានមួយ ដែលតម្រូវឱ្យបុគ្គលិកគ្រប់រូប គ្រប់ថ្នាក់អនុវត្តតាម។ ឯកសារនេះ មានបញ្ជាក់ច្បាស់ពីគោលបំណង និងទិសដៅលទ្ធផលជាក់ស្តែងដែលផ្សារភ្ជាប់និងមូលហេតុច្បាស់លាស់ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | ការវាយតម្លៃ | មាន - មិនមាន (*) | |

| | | | |
|---|---|---|---|
| **២១- ផែនការត្រួតពិនិត្យ និងតាមដានការបំពុលបរិយាកាសក្នុងដំណើរការអាជីវកម្ម** | សម្ភារៈបរិក្ខានៅក្នុងបរិវេណការិយាល័យខាងមុខជាឧបករណ៍ដែលមិនបំពុលខ្យល់ ឬមានការបំពុលតិចតួច | អាជីវកម្មបាននិងកំពុងប្រើប្រាស់បច្ចេកទេស ឬឧបករណ៍ ដែលមិនបំពុលខ្យល់ ឬមានការបំពុលតិចតួចនៅការិយាល័យជួរមុខ | - មានបញ្ជីឈ្មោះបច្ចេកទេស ឬឧបករណ៍ដែលប្រើប្រាស់នៅការិយាល័យជួរមុខ<br>- មានបញ្ជាក់បរិមាណជាភាគរយធៀបនឹងសម្ភារៈសរុបដែលកំពុងប្រើប្រាស់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៥០% | |
| | សម្ភារៈបរិក្ខានៅក្នុងបរិវេណបន្ទប់ស្នាក់ជាឧបករណ៍ ដែលមិនបំពុលខ្យល់ ឬមានការបំពុលតិចតួច | អាជីវកម្មបាននិងកំពុងប្រើប្រាស់សម្ភារៈបរិក្ខាដែលមិនបំពុលខ្យល់ ឬមានការបំពុលតិចតួចនៅក្នុងបន្ទប់ស្នាក់នៅ | - មានបញ្ជីឈ្មោះសម្ភារៈបរិក្ខាដែលប្រើប្រាស់ក្នុងបន្ទប់ស្នាក់នៅ |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៥០% | |
| | ចូលរួមជាប់ជាប្រចាំជាមួយក្រសួងទេសចរណ៍ក្នុងចលនា "ទេសចរម្នាក់ដើមឈើមួយដើម" | អាជីវកម្មបាននិងកំពុងចូលរួមជាប្រចាំក្នុងយុទ្ធនាការនេះជាមួយអាជ្ញាធរមូលដ្ឋាន ឬរៀបចំដោយអាជីវកម្មផ្ទាល់ ដោយមានជារូបភាពបញ្ជាក់អមជាមួយកាលបរិច្ឆេទចូលរួម ឬមានរៀបចំជាកម្មវិធីដាំដើមឈើនៅក្នុងការប្រតិបត្តិការអាជីវកម្មសណ្ឋាគារដោយមានឯកសារសំអាង (ឯកសាររបាយការណ៍ ឬជាផែនការនៃការអនុវត្តដែលមានការទទួលស្គាល់ត្រឹមត្រូវ) | - មានលិខិតបញ្ជាក់ការចូលរួម ឬមានកម្មវិធីសកម្មភាពច្បាស់លាស់និងបច្ចុប្បន្នភាព ឬមានរូបភាពបញ្ជាក់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន (*)** | |

## ៩. សូចនាករគោលនៃការគ្រប់គ្រងការបំពុលបរិស្ថានដោយសម្លេង

| សូចនាករលម្អិត | លក្ខណវិនិច្ឆ័យ | សូចនាករខ្វាស់ | លក្ខខណ្ឌ |
|---|---|---|---|
| **២២-ផែនការត្រួតពិនិត្យ និងតាមដានការបំពុលបរិស្ថានដោយសម្លេង** | វត្តមានគោលការណ៍អំពីការទប់ស្កាត់ការរំខានដោយសម្លេង (ខាងក្នុង និងខាងក្រៅ) | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានមួយ ដែលតម្រូវឱ្យបុគ្គលិកគ្រប់រូប គ្រប់ថ្នាក់អនុវត្តតាម។ ឯកសារនេះ មានបញ្ជាក់ច្បាស់ពីគោលបំណង និងទិសដៅលទ្ធផលជាក់ស្តែងដែលផ្សារភ្ជាប់នឹងមូលហេតុច្បាស់លាស់ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន-មិនមាន** (*) | |
| | បន្ទប់ស្នាក់មានឧបករណ៍ការពារសម្លេងមិនឱ្យជ្រៀតចេញ និងចូលបាន | អាជីវកម្មបាននិងកំពុងប្រើប្រាស់ឧបករណ៍ដែលការពារសម្លេងមិនឱ្យជ្រៀតចេញ និងចូលបាននៅក្នុងបន្ទប់ស្នាក់ | - មានបញ្ជីឈ្មោះឧបករណ៍ការពារសម្លេងរំខាន ដែលប្រើប្រាស់ក្នុងបន្ទប់ស្នាក់<br>- មានបញ្ជាក់បរិមាណសម្ភារៈសរុបដែលកំពុងប្រើប្រាស់ |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |
| | មានវិធីសាស្ត្រការពារសម្លេងរំខានដោយម៉ាស៊ីនភ្លើង | អាជីវកម្មបានប្រើប្រាស់មធ្យោបាយ ឬបច្ចេកទេសផ្សេងៗ ដើម្បីការពារសម្លេងរំខានដោយម៉ាស៊ីនភ្លើង | - មានឯកសារបញ្ជាក់អំពីមធ្យោបាយ ឬរបៀបប្រើប្រាស់បច្ចេកទេស |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |
| | ប្រើប្រាស់វិធីសាស្ត្រសំណង់ដែលការពារសម្លេងមិនឱ្យជ្រៀតចេញ និងចូលបាន | អាជីវកម្មបានប្រើប្រាស់បច្ចេកទេសសំណង់ ដែលការពារសម្លេងមិនឱ្យជ្រៀតចេញ និងចូលបាន | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

## ១០. សូចនាករគោលនៃការគ្រប់គ្រង និងការធ្វើប្រព្រឹត្តកម្មសំណល់រាវ

| សូចនាករលម្អិត | លក្ខណវិនិច្ឆ័យ | សូចនាករវាស់ | លក្ខខណ្ឌ |
|---|---|---|---|
| **២៣-យន្តការការពារ និងកាត់បន្ថយការបំពុលទឹក** | វត្តមានយន្តការការពារ និងកាត់បន្ថយការបំពុលទឹក | អាជីវកម្មបានរៀបចំជាយន្តការការពារ និងផែនការកាត់បន្ថយការបំពុលទឹក។ យន្តការការពារ និងផែនការកាត់បន្ថយការបំពុលទឹក ត្រូវកំណត់ទិសដៅលទ្ធផលច្បាស់លាស់។ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន-មិនមាន** (*) | |
| | សម្ភារៈប្រើប្រាស់ក្នុងបន្ទប់ស្នាក់នៅជាសម្ភារៈដែលគ្មានសារធាតុបំពុលទឹក ឬបំពុលតិចតួច | អាជីវកម្មបាននិងកំពុងប្រើប្រាស់ឧបករណ៍ ឬសម្ភារៈដែលគ្មានសារធាតុបំពុលទឹក ឬបំពុលទឹកតិចតួច នៅក្នុងបន្ទប់ស្នាក់ | - មានបញ្ជីឈ្មោះឧបករណ៍ ឬសម្ភារៈ ដែលគ្មានសារធាតុពុល ឬបំពុលទឹកតិចតួច ដែលប្រើប្រាស់ក្នុងបន្ទប់ស្នាក់<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោច៥០% | |
| **២៤-ការធ្វើប្រព្រឹត្តិកម្មសំណល់រាវ** | មានអាងស្តុកសំណល់រាវ | អាជីវកម្មមានរៀបចំជាអាងស្តុកសំណល់រាវ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន**<br>យ៉ាងហោចស្តុកបាន ៥០%នៃបរិមាណសំណល់រាវសរុប | |
| | មានប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវសមមាត្រនឹងចំណុះស្តុក (*wastewater treatment system*) | អាជីវកម្មមានរៀបចំប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវសមមាត្រនឹងចំណុះស្តុក | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

| | | | |
|---|---|---|---|
| **២៥- យន្តការលើកទឹកចិត្តឱ្យមានការប្រើប្រាស់សំណល់រាវដែលធ្វើប្រតិបត្តិកម្មរួចឡើងវិញ** | សំណល់រាវដែលបានធ្វើប្រតិបត្តិកម្មរួចត្រូវបានប្រើប្រាស់ឡើងវិញដោយសណ្ឋាគារដោយផ្ទាល់ | អាជីវកម្មមានឯកសារបញ្ជាក់អំពីគុណភាពទឹកដែលបានធ្វើប្រព្រឹត្តកម្មរួចនិងសកម្មភាពនៃការប្រើប្រាស់ទឹកបានធ្វើប្រព្រឹត្តកម្ម | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន -មិនមាន** | |

## ១១. សូចនាករគោលនៃការគ្រប់គ្រងផលិតផល និងសំណល់ ដែលមានសារធាតុគីមី និងជាតិពុល

| **សូចនាករលម្អិត** | **លក្ខណវិនិច្ឆ័យនៃការវាយតម្លៃ** | **សូចនាកររង្វាស់** | **លក្ខខណ្ឌ** |
|---|---|---|---|
| **២៦-ការគ្រប់គ្រងការប្រើប្រាស់ផលិតផលគីមី និងមានសារធាតុពុល** | វត្តមានគោលការណ៍ជៀសវាង ឬកាត់បន្ថយការប្រើប្រាស់ផលិតផលគីមី ឬមានសារធាតុពុល | អាជីវកម្មបានរៀបចំរួចរាល់នូវឯកសារជាមូលដ្ឋានមួយ ដែលតម្រូវឱ្យបុគ្គលិកគ្រប់រូប គ្រប់ថ្នាក់អនុវត្តតាម។ ឯកសារនេះ មានបញ្ជាក់ច្បាស់ពីគោលបំណង និងទិសដៅលទ្ធផល ជាក់ស្តែងដែលផ្សារភ្ជាប់នឹងមូលហេតុដើម្បីលើកកម្ពស់គុណភាពបរិស្ថាន | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន -មិនមាន (*)** | |
| | ផលិតផលប្រើប្រាស់សម្រាប់ផ្គត់ផ្គង់សេវាកម្មបន្ទប់ មិនមែនជាផលិតផលគីមី ឬមានជាតិពុល | អាជីវកម្មបាននិងកំពុងប្រើប្រាស់ផលិតផល ដែលមិនមែនជាផលិតផលគីមី ឬមានជាតិពុល សម្រាប់សេវាកម្មបន្ទប់ស្នាក់នៅ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន -មិនមាន**<br>យ៉ាងហោច៥0% | |

| | | | |
|---|---|---|---|
| ២៧- ការគ្រប់គ្រងការប្រើប្រាស់ផលិតផលគីមី និងមានសារធាតុពុល | ផលិតផលគីមី និងមានសារធាតុពុលត្រូវមានបិទស្លាកសញ្ញាសម្គាល់ស្របទៅនឹងច្បាប់ជាតិដែលបានកំណត់ | អាជីវកម្មបានបិទបង្ហាញគ្រប់ផលិតផលគីមី និងសារធាតុពុល ស្របតាមការកំណត់ដោយស្ថាប័ន អង្គភាពមានសមត្ថកិច្ច | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |
| | ផ្តល់ព័ត៌មានជូនភ្ញៀវអំពីគោលការណ៍ របស់សណ្ឋាគារមិនលើកទឹកចិត្តដល់ការប្រើប្រាស់ផលិតផលគីមី និងមានសារធាតុពុល | អាជីវកម្មបានរៀបចំមធ្យោបាយ ដើម្បីជូនព័ត៌មានទៅភ្ញៀវអំពីគោលការណ៍មិនលើកទឹកចិត្តដល់ការប្រើប្រាស់ផលិតផលគីមី និងមានសារធាតុពុល | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |
| ២៨- ការគ្រប់គ្រងសំណល់គីមី និងមានសារធាតុពុល | មានកន្លែងសុវត្ថិភាពសម្រាប់ទុកដាក់សំណល់គីមី ឬមានជាតិពុលដាច់ដោយឡែក និងឆ្ងាយពីកន្លែងមានមនុស្សឆ្លងកាត់ញឹកញាប់ | អាជីវកម្មបានរៀបចំទីតាំងជាក់លាក់សម្រាប់ទុកដាក់សំណល់គីមី ឬមានជាតិពុលដាច់ដោយឡែក ដោយមានបញ្ជាក់អំពីវិធីសាស្ត្រវេចខ្ចប់បានត្រឹមត្រូវ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន (*)** | |
| | សំណល់គីមី ឬមានជាតិពុលត្រូវបានបញ្ចេញចោល ឬបំផ្លាញចោលតាមការណែនាំរបស់បទដ្ឋានថ្នាក់ជាតិជាធរមាន | អាជីវកម្មបានរៀបចំការទុកដាក់សំណល់គីមីដោយមានកត់ត្រាបរិមាណប្រចាំថ្ងៃ និងប្រចាំខែបានច្បាស់លាស់ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ)<br>- រូបភាព |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

| | | | |
|---|---|---|---|
| | ផែនការកាត់បន្ថយសំណល់គីមី ឬមានជាតិពុលសម្រាប់ឆ្នាំបន្ទាប់ | អាជីវកម្មបានរៀបចំជាផែនការកម្មវិធី ឬសកម្មភាពការងារ កាត់បន្ថយសំណល់គីមី ឬមានជាតិពុលសម្រាប់ឆ្នាំបន្ទាប់ | - មានឯកសារបង្ហាញជាផ្លូវការ (មានត្រាបញ្ជាក់ ឬបានបោះផ្សាយ ឬផ្សព្វផ្សាយជាទម្រង់ផ្លូវការ) |
| | **ការវាយតម្លៃ** | **មាន-មិនមាន** | |

- **សំគាល់៖ គ្រប់ឯកសារទាំងអស់ដែលមានក្នុងសេចក្តីពន្យល់នៃលក្ខណៈវិនិច្ឆ័យនីមួយៗ ត្រូវមានការទទួលស្គាល់ពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់សណ្ឋាគារ (Top Management) តាមរយៈការបោះត្រារបស់សណ្ឋាគារ ឬហត្ថលេខារបស់ថ្នាក់ដឹកនាំ។**
- **ការវាយតម្លៃស្តង់ដាសណ្ឋាគារបៃតងកម្ពុជា៖**
  - ០១ លក្ខណវិនិច្ឆ័យ ស្មើនឹង ០១ ពិន្ទុ។
  - សណ្ឋាគារដែលមានអាជ្ញាបណ្ណទេសចរណ៍ អាចទទួលបានអេកូឡាបិលស្តង់ដាសណ្ឋាគារបៃតងកម្ពុជាបាន លុះត្រាតែអនុវត្តបានចាប់ពី **៤៤ លក្ខណវិនិច្ឆ័យឡើង (ស្មើនឹង ៦០%)** ក្នុងចំណោមលក្ខណវិនិច្ឆ័យសរុបចំនួន **៧៣** ដោយរួមបញ្ចូលទាំង **២០ លក្ខណវិនិច្ឆ័យតម្រូវចាំបាច់**។
  - សណ្ឋាគារដែលមានចំណាត់ថ្នាក់ផ្កាយ៤ ឬផ្កាយ៥ នឹងទទួលបានអេកូឡាបិលស្តង់ដាសណ្ឋាគារបៃតងកម្ពុជាបាន លុះត្រូវតែបំពេញឱ្យបាននូវ **២០ លក្ខណវិនិច្ឆ័យតម្រូវចាំបាច់**នៃស្តង់ដាសណ្ឋាគារបៃតងកម្ពុជា។